ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ :...០៣៦ សណន

# សេចក្តីណែនាំ
## ស្តីពី
## ការបង្កើត ការអនុវត្តតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក

យោងមាត្រា១១៤ និងមាត្រា១២៦នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ២១៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាស្រុក។

ការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សានៅថ្នាក់រដ្ឋបាលទាំងនេះ គឺជាការរៀបចំឱ្យមានប្រព័ន្ធដ៏សមស្របមួយ ដើម្បីធានាឱ្យមានការពិគ្រោះយោបល់ ការចូលរួម ការសម្របសម្រួលក្នុងចំណោមអ្នកពាក់ព័ន្ធនានា ក្នុងការរៀបចំផែនការ ថវិកា ការប្រគល់មុខងារនិងធនធាន ការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងរដ្ឋបាលឯកភាពតាមថ្នាក់នីមួយៗ ការសម្របសម្រួលកិច្ចការរបស់ក្រុមប្រឹក្សាជាមួយមន្ទីរ អង្គភាព ការិយាល័យជំនាញនានា ព្រមទាំងកិច្ចសហប្រតិបត្តិការនិងការពិគ្រោះយោបល់រវាងក្រុមប្រឹក្សាប្រភេទដូចគ្នា និងក្រុមប្រឹក្សាប្រភេទផ្សេងៗទៀត។ ផ្អែកលើមូលដ្ឋាននេះ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសគឺជាយន្តការប្រកបដោយប្រសិទ្ធិភាព នឹងផ្តល់យោបល់ជូនក្រុមប្រឹក្សារបស់ខ្លួន ដើម្បីជាមូលដ្ឋាននៃការធ្វើសេចក្តីសម្រេចនានាក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានតាមបែបប្រជាធិបតេយ្យ សំដៅឆ្លើយតបទៅនឹងតម្រូវការប្រជាពលរដ្ឋ និងរួមចំណែកកាត់បន្ថយភាពក្រីក្រ។

រហូតមកទល់ពេលនេះ ក្រសួងមហាផ្ទៃបានពិនិត្យ សម្រេចធ្វើសមាហរណកម្មនិងរៀបចំមុខតំណែងមន្ត្រីរាជការដែលកំពុងបម្រើការងារនៅតាមសាលាខេត្ត សាលាក្រុង សាលាស្រុក រួចរាល់ជាស្ថាពរ។ បន្ទាប់ពីបានប្រារព្ធពិធីប្រកាសមុខតំណែង មន្ត្រីរាជការ ទៅក្នុងរចនាសម្ព័ន្ធសាលាខេត្ត សាលាក្រុង សាលាស្រុករួចមក សាលាខេត្ត សាលាក្រុង សាលាស្រុក បានដំណើរការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនស្របទៅតាមលិខិតបទដ្ឋានដែលបានកំណត់។ ប៉ុន្តែ ដើម្បីធានាឱ្យប្រព័ន្ធអភិបាលកិច្ចនៃរដ្ឋបាលខេត្ត ក្រុង ស្រុក ប្រព្រឹត្តទៅកាន់តែមានប្រសិទ្ធភាពថែមទៀត និងដើម្បីអនុវត្តច្បាប់ រៀបចំអង្គការនិងលិខិតបទដ្ឋានដែលបានកំណត់ ចាំបាច់ត្រូវបន្តរៀបចំបង្កើតឡើងនូវគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ដែលក្នុងនោះចាំបាច់គឺការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ។

ដើម្បីជួយដល់រដ្ឋបាលខេត្ត ក្រុង ស្រុកក្នុងការរៀបចំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ខ្លួន ស្របតាមស្មារតីមាត្រា៣០នៃអនុក្រឹត្យលេខ២១៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំអំពីការបង្កើត ការអនុវត្តតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ដូចខាងក្រោម :

## ក. សមាសភាពគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

១). គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាខេត្ត មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| – អភិបាលខេត្ត | ជាប្រធាន |
| – អភិបាលរងខេត្ត០១រូប | ជាអនុប្រធាន |
| – នាយករដ្ឋបាលសាលាខេត្ត | ជាសមាជិកអចិន្ត្រៃយ៍ |
| – សមាជិកក្រុមប្រឹក្សាខេត្តយ៉ាងតិច០២រូប | ជាសមាជិក |
| – ប្រធានមន្ទីរ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលដែលប្រចាំនៅខេត្ត | ជាសមាជិក |
| – នាយកទីចាត់ការទាំងអស់របស់សាលាខេត្ត | ជាសមាជិក |
| – អភិបាលក្រុងនិងអភិបាលស្រុកទាំងអស់នៅក្នុងខេត្ត | ជាសមាជិក |
| – តំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំខេត្ត០២រូប | ជាសមាជិក |
| – តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមាររបស់ក្រុមប្រឹក្សាខេត្ត០១រូប | ជាសមាជិក។ |

២). គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាក្រុង មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| – អភិបាលក្រុង | ជាប្រធាន |
| – អភិបាលរងក្រុង០១រូប | ជាអនុប្រធាន |
| – នាយករដ្ឋបាលសាលាក្រុង | ជាសមាជិកអចិន្ត្រៃយ៍ |
| – សមាជិកក្រុមប្រឹក្សាក្រុងយ៉ាងតិច០២រូប | ជាសមាជិក |
| – ប្រធានការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលដែលប្រចាំនៅក្រុង | ជាសមាជិក |
| – ប្រធានការិយាល័យទាំងអស់របស់សាលាក្រុង | ជាសមាជិក |
| – ចៅសង្កាត់ទាំងអស់នៅក្នុងក្រុង | ជាសមាជិក |
| – តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមាររបស់ក្រុមប្រឹក្សាក្រុង០១រូប | ជាសមាជិក។ |

៣). គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាស្រុក មានសមាសភាពដូចខាងក្រោម :

- អភិបាលស្រុក ជាប្រធាន
- អភិបាលរងស្រុក០១រូប ជាអនុប្រធាន
- នាយករដ្ឋបាលសាលាស្រុក ជាសមាជិកអចិន្ត្រៃយ៍
- សមាជិកក្រុមប្រឹក្សាស្រុកយ៉ាងតិច០២រូប ជាសមាជិក
- ប្រធានការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដែលប្រចាំនៅស្រុក ជាសមាជិក
- ប្រធានការិយាល័យទាំងអស់របស់សាលាស្រុក ជាសមាជិក
- មេឃុំ ចៅសង្កាត់ទាំងអស់នៅក្នុងស្រុក ជាសមាជិក
- តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាស្រុក០១រូប ជាសមាជិក។

អភិបាលខេត្ត អភិបាលក្រុង អភិបាលស្រុកត្រូវពិភាក្សាក្នុងគណៈអភិបាលរបស់ខ្លួន ជ្រើសរើសអភិបាលរងខេត្ត ក្រុង ស្រុកមួយរូប ដែលទទួលជួយកិច្ចការផែនការ វិនិយោគ និងអភិវឌ្ឍន៍ ដើម្បីស្នើជាអនុប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក។

ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុកត្រូវប្រជុំសាមញ្ញ ឬវិសាមញ្ញ ដើម្បីរៀបចំសមាសភាពសមាជិកក្រុមប្រឹក្សារបស់ខ្លួន សម្រាប់ចូលរួមជាសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស។ តំណាងសមាជិកក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ដែលចូលរួមក្នុងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសត្រូវមានចំនួនដូចខាងក្រោម :

- ខេត្ត ក្រុង ស្រុកដែលមានសមាជិកក្រុមប្រឹក្សាពី១៩រូប ដល់២១រូប ត្រូវមានចំនួន ០៤រូប
- ខេត្ត ក្រុង ស្រុកដែលមានសមាជិកក្រុមប្រឹក្សាពី១៣រូប ដល់១៧រូប ត្រូវមានចំនួន ០៣រូប
- ខេត្ត ក្រុង ស្រុកដែលមានសមាជិកក្រុមប្រឹក្សាពី០៧រូប ដល់១១រូប ត្រូវមានចំនួន ០២រូប។

សមាជិកក្រុមប្រឹក្សាទាំងនេះ ត្រូវមានសមាសភាពមកពីគណបក្សដែលមានអាសនៈក្នុងក្រុមប្រឹក្សា និងត្រូវមានសមាជិកក្រុមប្រឹក្សាជាស្ត្រីក្នុងករណីក្រុមប្រឹក្សាមានស្ត្រីជាសមាជិក ។

តំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំខេត្ត០២រូប ដែលត្រូវជ្រើសរើសឱ្យចូលរួមជាសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត ត្រូវចាត់តាំងដោយគណៈកម្មាធិការប្រតិបត្តិនៃសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំខេត្ត។ តំណាងទាំងពីររូបនេះត្រូវមានស្ត្រីមួយរូប។

តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ត្រូវចាត់តាំងដោយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការពិគ្រោះយោបល់ស្ត្រីនិងកុមារក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងត្រូវសម្រេចដោយក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក។ ៕

ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុកត្រូវរៀបចំប្រជុំក្រុមប្រឹក្សារបស់ខ្លួន ដើម្បីពិនិត្យ និងអនុម័តសេចក្តីសម្រេចទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក( ដូចមានគំរូជូនភ្ជាប់ជាមួយ) ។ សេចក្តីសម្រេចនេះត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក។

សេចក្តីសម្រេចទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាខេត្ត ត្រូវចម្លងជូនលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័នដែលពាក់ព័ន្ធ។ ដោយឡែកចំពោះសេចក្តីសម្រេចទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាក្រុង ស្រុក ត្រូវចម្លងជូនសាលាខេត្តរបស់ខ្លួន និងលេខាធិការដ្ឋាន គ.ជ.អ.ប។

ក្នុងករណីមានការបន្ថែម ឬមានការផ្លាស់ប្តូរសមាជិកនៅក្នុងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សាត្រូវចេញសេចក្តីសម្រេចជាថ្មី ដើម្បីទទួលស្គាល់ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ទៅតាមនីតិវិធីដូចបានកំណត់ខាងលើ។

## ខ. តួនាទី ភារកិច្ចរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក មានតួនាទី ភារកិច្ចផ្តល់យោបល់ដល់ក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត ក្រុង ស្រុកលើកិច្ចការសំខាន់ៗ ដែលបានកំណត់នៅក្នុងមាត្រា៤ មាត្រា១៣ និងមាត្រា២២ នៃអនុក្រឹត្យលេខ ២១៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ដូចខាងក្រោម :

- ផែនការអភិវឌ្ឍន៍និងថវិកា
- សម្របសម្រួលកិច្ចការរបស់ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ជាមួយមន្ទីរ អង្គភាព ការិយាល័យរបស់ក្រសួងស្ថាប័ននានា
- កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលនៅក្នុងរដ្ឋបាលឯកភាពខេត្ត ក្រុង ស្រុក
- កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលរវាងក្រុមប្រឹក្សាខេត្ត ជាមួយក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងខេត្ត កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលរវាងក្រុមប្រឹក្សាក្រុង ស្រុក ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងក្រុង ស្រុក និងក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់
- កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលរវាងក្រុមប្រឹក្សាខេត្ត ក្រុង ស្រុកជាមួយក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត ពិសេសខេត្ត ក្រុង ស្រុក ជាប់ព្រំប្រទល់ជាមួយគ្នា
- ការងារទាក់ទងមុខងារនិងធនធាន
- កិច្ចការមួយចំនួនទៀតដែលតម្រូវដោយច្បាប់និងលិខិតបទដ្ឋានផ្សេងៗ។

**១). តួនាទី និងភារកិច្ចរបស់ប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**

ប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មានតួនាទី និងភារកិច្ច :

- កោះប្រជុំ និងដឹកនាំរាល់កិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស។ ក្នុងករណីប្រធានអវត្តមាន ប្រធានត្រូវផ្ទេរសិទ្ធិជូនអនុប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីកោះប្រជុំ និងដឹកនាំកិច្ចប្រជុំជំនួស។
- កំណត់អំពីរបៀបវារៈប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ស្របតាមមាត្រា៨ មាត្រា៩ មាត្រា១៧ មាត្រា១៨ មាត្រា២៦ និងមាត្រា២៧ នៃអនុក្រឹត្យលេខ ២១៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៩
- កំណត់អំពីអ្នកពាក់ព័ន្ធនានាដែលត្រូវអញ្ជើញចូលរួមប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- ទទួលខុសត្រូវរួមក្នុងការបំពេញតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- ណែនាំ លើកទឹកចិត្ត និងត្រួតពិនិត្យដល់អនុប្រធាន សមាជិក អនុគណៈកម្មាធិការ និងក្រុមការងាររបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន
- ត្រូវធានាឱ្យគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក អនុវត្តត្រឹមត្រូវនូវតួនាទី ដូចបានកំណត់ក្នុងមាត្រា៤ មាត្រា១៣ និងមាត្រា២២ នៃអនុក្រឹត្យលេខ ២១៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៩ ។

**២). តួនាទី និងភារកិច្ចរបស់អនុប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**

អនុប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មានតួនាទី និងភារកិច្ច :

- ចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- ជំនួសប្រធាន ពេលប្រធានអវត្តមាន តាមការផ្ទេរសិទ្ធិពីប្រធាន
- សហការ គាំទ្រដល់សមាជិកអចិន្ត្រៃយ៍ក្នុងការរៀបចំកិច្ចប្រជុំ និងឯកសារពាក់ព័ន្ធនានា សម្រាប់កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដូចមានចែងក្នុងមាត្រា៨ មាត្រា៩ មាត្រា១៧ មាត្រា១៨ មាត្រា២៦ និងមាត្រា២៧ នៃអនុក្រឹត្យលេខ ២១៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៩
- ពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងឯកសារពាក់ព័ន្ធនានា មុននឹងដាក់ជូនអង្គប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- បំពេញកិច្ចការផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីប្រធាន។

**៣). តួនាទី និងភារកិច្ចរបស់សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**

សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មានតួនាទី និងភារកិច្ច :

- សម្របសម្រួលលើកិច្ចការរដ្ឋបាលប្រចាំថ្ងៃ និងការរៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- សម្របសម្រួលក្នុងការសិក្សាស្រាវជ្រាវ និងលើកយោបល់ជូនគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស អំពីការងារផែនការ ថវិកា កិច្ចសហប្រតិបត្តិការ ការសម្របសម្រួល ការរៀបចំយន្តការពិគ្រោះយោបល់ ការផ្តួចផ្តើមស្នើឡើងនូវមុខងារ និងធនធានដែលគួរត្រូវបានប្រគល់ ឬបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ និងភារកិច្ចនានារបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដូចមានចែងក្នុងមាត្រា៨ មាត្រា១៣ និងមាត្រា២២ នៃអនុក្រឹត្យលេខ ២១៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៩
- សម្របសម្រួលក្នុងការសិក្សាស្រាវជ្រាវ និងលើកយោបល់ជូនគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស អំពីការផ្តល់សេវា និងការអភិវឌ្ឍនៅមូលដ្ឋានរបស់មន្ទីរ ការិយាល័យ អង្គភាពរបស់ក្រសួង ស្ថាប័ននានា
- រៀបចំកំណត់ហេតុប្រជុំ និងរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីដាក់ជូនក្រុមប្រឹក្សា និងគណៈអភិបាល
- ដឹកនាំទីចាត់ការ ការិយាល័យពាក់ព័ន្ធនានានៅក្នុងសាលាខេត្ត ក្រុង ស្រុក ដោយសហការជាមួយមន្ទីរ អង្គភាព ការិយាល័យ និងអ្នកពាក់ព័ន្ធនានា សិក្សាស្រាវជ្រាវ និងរៀបចំឯកសារ បែបបទ នីតិវិធី ដើម្បីដាក់ជូនអង្គប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- បំពេញកិច្ចការផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីប្រធាន។

**៤). តួនាទី និងភារកិច្ចរបស់សមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**

សមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មានតួនាទី និងភារកិច្ច :

- ចូលរួមនៅក្នុងកិច្ចប្រជុំនានារបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- ផ្តល់មតិយោបល់ និងអនុសាសន៍នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- ចូលរួមសិក្សាស្រាវជ្រាវ និងរៀបចំឯកសារពាក់ព័ន្ធនានាសម្រាប់កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- ដឹកនាំ និងសម្របសម្រួលអនុវត្តការសម្រេចនានារបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដែលបានអនុម័តដោយក្រុមប្រឹក្សានៅអង្គភាពរបស់ខ្លួន
- បំពេញកិច្ចការផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីប្រធាន។

## គ. របៀបរបបការងាររបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ត្រូវជួបប្រជុំយ៉ាងតិចពីរខែម្តង។ កិច្ចប្រជុំអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការសម្រប

សម្រួលបច្ចេកទេសទាំងមូល ។

ប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ ។

សេចក្តីសម្រេចនៃកិច្ចប្រជុំអាចយកជាការបាន លុះត្រាមានសម្លេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសទាំងមូល ។ ក្នុងករណីសម្លេងស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព ។ ការអនុម័តលើសេចក្តីសម្រេចនីមួយៗ ត្រូវធ្វើឡើងតាមរយៈការលើកដៃ ។

គ្រប់កិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ត្រូវមានកំណត់ហេតុដែលរៀបចំឡើងដោយសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ហើយត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ ។

គណៈកម្មាធិការអាចកំណត់អំពីរបៀបរបបប្រជុំ ការអនុម័ត របៀបរបបការងារជាក់ស្តែង និងការបែងចែកភារកិច្ចដល់សមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសតាមការចាំបាច់ ។

ក្នុងករណីសមាជិកណាមួយនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាខេត្ត ដែលជានាយករដ្ឋបាលសាលាខេត្ត អភិបាលក្រុង ស្រុក ប្រធានមន្ទីរ អង្គភាពនៃក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាលប្រចាំនៅខេត្ត នាយកទីចាត់ការនៃសាលាខេត្ត អវត្តមាន សមាជិកនោះអាចចាត់តំណាងដែលមានសិទ្ធិសម្រេចជំនួសខ្លួនឱ្យចូលរួមប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសបាន ។

ក្នុងករណីសមាជិកណាមួយនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាក្រុង ស្រុក ដែលជានាយករដ្ឋបាលសាលាក្រុង ស្រុក ប្រធានការិយាល័យអង្គភាពនៃក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាលប្រចាំនៅក្រុង ស្រុក និងប្រធានការិយាល័យសាលាក្រុង ស្រុក អវត្តមាន សមាជិកនោះអាចចាត់តំណាងដែលមានសិទ្ធិសម្រេចជំនួសខ្លួនឱ្យចូលរួមប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសបាន ។

អភិបាលខេត្ត ក្រុង ស្រុក អាចស្នើឱ្យអភិបាលរងខេត្ត ក្រុង ស្រុក មន្ត្រី ទីប្រឹក្សាបច្ចេកទេស និងអ្នកពាក់ព័ន្ធនានាចូលរួមកិច្ចប្រជុំគណៈកម្មាធិការនេះតាមការចាំបាច់ ។ អភិបាលរងខេត្ត ក្រុង ស្រុក មន្ត្រី ទីប្រឹក្សាបច្ចេកទេស និងអ្នកពាក់ព័ន្ធទាំងនោះអាចផ្តល់យោបល់នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការបាន ប៉ុន្តែពុំមានសិទ្ធិអនុម័តឡើយ ។

កិច្ចប្រជុំនីមួយៗរបស់គណៈកម្មាធិការត្រូវមានរបៀបវារៈដែលបានត្រៀមរៀបចំជាមុន ។

អភិបាលខេត្ត ក្រុង ស្រុក ដោយមាននាយករដ្ឋបាលសាលាខេត្ត ក្រុង ស្រុកជាជំនួយការ ត្រូវរៀបចំរបៀបវារៈប្រជុំដោយផ្អែកតាម :

- តម្រូវការរបស់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក
- តម្រូវការរបស់គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក
- តម្រូវការរបស់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក

- សំណើរបស់សមាជិកយ៉ាងតិចមួយភាគបី នៃចំនួនសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក
- តម្រូវការនៃច្បាប់ឬលិខិតបទដ្ឋានគតិយុត្ត។

ផ្អែកតាមតម្រូវការ និងសំណើដូចខាងលើនេះ អភិបាលខេត្ត អភិបាលក្រុង អភិបាលស្រុក ត្រូវពិគ្រោះយោបល់នៅក្នុងគណៈអភិបាលរបស់ខ្លួន ដើម្បីចាត់ឱ្យទីចាត់ការ ការិយាល័យមួយ ឬច្រើនដែលពាក់ព័ន្ធនៃសាលាខេត្ត សាលាក្រុង សាលាស្រុក សិក្សា រៀបចំឯកសារ បែបបទ នីតិវិធីនានា តាមរបៀបវារៈនីមួយៗ។

នាយករដ្ឋបាលសាលាខេត្ត ក្រុង ស្រុក ត្រូវដឹកនាំទីចាត់ការ ការិយាល័យដែលពាក់ព័ន្ធនៅក្នុងសាលាខេត្ត ក្រុង ស្រុក សិក្សា រៀបចំឯកសារ បែបបទ នីតិវិធីខាងលើនេះ ដោយសហការជាមួយមន្ទីរ អង្គភាព ការិយាល័យ និងរដ្ឋបាលដែលពាក់ព័ន្ធនានាតាមការចាំបាច់។ ក្នុងការសិក្សារៀបចំឯកសារ បែបបទ នីតិវិធី នាយករដ្ឋបាលសាលាខេត្ត ក្រុង ស្រុក ត្រូវផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តច្បាប់ទាំងនេះ។

ក្រោយពេលរៀបចំឯកសារ បែបបទ នីតិវិធីតាមរបៀបវារៈនីមួយៗរួចហើយ នាយករដ្ឋបាលសាលាខេត្ត ក្រុង ស្រុក ត្រូវដាក់ជូនអភិបាលខេត្ត អភិបាលក្រុង អភិបាលស្រុក ដើម្បីពិនិត្យ និងរៀបចំកោះប្រជុំគណៈកម្មាធិការ។

អភិបាលខេត្ត អភិបាលក្រុង អភិបាលស្រុក ដោយមាននាយករដ្ឋបាលសាលាខេត្ត ក្រុង ស្រុក ជាជំនួយការ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មាធិការ ដើម្បីដាក់ជូនក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ចំពោះកិច្ចការទាំងឡាយណាដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ឬដាក់ជូនគណៈអភិបាលខេត្ត ក្រុង ស្រុក ចំពោះកិច្ចការទាំងឡាយណាដែលជាសមត្ថកិច្ចរបស់គណៈអភិបាលខេត្ត ក្រុង ស្រុក។ របាយការណ៍លទ្ធផលនៃកិច្ចប្រជុំនេះត្រូវផ្ញើជូនសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសទាំងអស់។

## ឃ. ការបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារ

ដើម្បីជួយសម្រួលដល់កិច្ចការរបស់ខ្លួន គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុកអាចស្នើសុំបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារតាមការចាំបាច់ ឬតាមតម្រូវការនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

សមាសភាពអនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ អាចជ្រើសចេញពីសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មន្ត្រីអង្គភាពពាក់ព័ន្ធនៃសាលាខេត្ត សាលាក្រុង សាលាស្រុក និងមន្ទីរ អង្គភាព ការិយាល័យពាក់ព័ន្ធនានា តាមការចាំបាច់។

ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុកត្រូវសម្រេចអំពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការ

ឬក្រុមការងារខាងលើនេះ។ សេចក្តីសម្រេចនេះត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ផ្អែកតាមការសម្រេចក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន។

## ខ. ការកសាងសមត្ថភាព

អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ដោយមានការគាំទ្រពីលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវធ្វើការគាំទ្រ និងផ្សព្វផ្សាយដល់ក្រុមប្រឹក្សា គណៈអភិបាល សមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងអ្នកពាក់ព័ន្ធនានា អំពីដំណើរការនៃការរៀបចំបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់គណៈកម្មាធិការនេះ។

ទទួលបានសេចក្តីណែនាំនេះ ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក និងអង្គភាពដែលពាក់ព័ន្ធ ត្រូវចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ ៥ ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- លេខាធិការដ្ឋាន គ.ជ.អ.ប
- សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាឃុំ សង្កាត់

  *"ដើម្បីជូនជ្រាប"*
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្ត/ក្រុង/ស្រុក.....................**

លេខ...............................

| |
|---|
| **គំរូសម្រាប់** |
| **ខេត្ត ក្រុង ស្រុក** |

# សេចក្តីសម្រេច

## ស្តីពី

## ការទទួលស្គាល់ប្រធាន អនុប្រធាន និងសមាជិក

## គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក........

*******

**ប្រធានក្រុមប្រឹក្សាខេត្ត/ក្រុង/ស្រុក......................**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក
- យោងសេចក្តីណែនាំលេខ..............ចុះថ្ងៃទី.......ខែ.........ឆ្នាំ២០១០ ស្តីពីការបង្កើត ការអនុវត្តតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក
- យោងស្មារតីនៃកិច្ចប្រជុំក្រុមប្រឹក្សាខេត្ត/ក្រុង/ស្រុក នាថ្ងៃទី .........ខែ ..............ឆ្នាំ..................

## ស ម្រេ ច

**ប្រការ១..**

ត្រូវបានទទួលស្គាល់ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក......... ដូចមានរាយនាមខាងក្រោម :

( **ស្នើបញ្ចូលសមាសភាពប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ សមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត/ក្រុង/ស្រុក ដូចបានកំណត់នៅក្នុងសេចក្តីណែនាំ** ) ។

**ប្រការ២..**

តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក .................. ត្រូវអនុវត្តឱ្យបានស្របទៅតាមអនុក្រឹត្យលេខ ២១៨ អនក្រ.បក និងសេចក្តីណែនាំ លេខ.......... ដូចមានយោងខាងលើ ។

**ប្រការ៣..**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេច នេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៤..**

គណៈអភិបាលខេត្តឬក្រុងឬស្រុក ប្រធានមន្ទីរ អង្គភាព ការិយាល័យជុំវិញខេត្តឬក្រុងឬស្រុក ទីចាត់ការ និង/ឬការិយាល័យចំណុះរចនាសម្ព័ន្ធសាលាខេត្តឬក្រុងឬស្រុក និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ០១ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

.................... *ថ្ងៃទី ខែ ឆ្នាំ ២០១០*

**ប្រធានក្រុមប្រឹក្សាខេត្ត/ក្រុង/ស្រុក.......**

**<u>ចម្លងជូន</u>**

- *ក្រសួងមហាផ្ទៃ*
- *ក្រសួង ស្ថាប័នពាក់ព័ន្ធ*
- *លេខាធិការដ្ឋាន គ.ជ.អ.ប*
- *ដូចប្រការ ៤*
- *ឯកសារ កាលប្បវត្តិ*